# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាខួប៤០០ឆ្នាំរបស់ក្រុមគ្រួសារវ៉ាំងសង់ឌឺប៉ូល
# ថ្ងៃទី១៩ កុម្ភៈ ២០១៧

អត្ថបទទី១៖ លវ ១៩,១-២.១៧-១៨
អត្ថបទទី២៖ ១ករ ៣,១៦-២៣
ដំណឹងល្អ៖ មថ ៥,៣៨-៤៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះព្រះយេស៊ូបានប្រកាស អំពីផ្លូវនៃសុភមង្គលលើភ្នំឱ្យយើងធ្វើជាពន្លឺឲ្យយើងធ្វើជាអំបិល ឲ្យយើងសុខចិត្តបំពេញធម្មវិន័យនៅក្នុងសេចក្ដីស្រឡាញ់។ ថ្ងៃនេះព្រះយេស៊ូបានអញ្ជើញយើង ឲ្យយើងមានលក្ខណៈដូចព្រះបិតា "**ព្រះបិតារបស់អ្នករាល់គ្នាដែលគង់នៅស្ថានបរមសុខទ្រង់គ្រប់លក្ខណៈយ៉ាងណា សូមឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណៈយ៉ាងនោះដែរ**"។ លក្ខខណ្ឌរបស់ព្រះជាម្ចាស់គឺ "**អ្នករាល់គ្នាត្រូវតែវិសុទ្ធ ព្រោះយើងជាព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នា យើងជាព្រះដ៏វិសុទ្ធ**"។ ដូច្នេះអាទិត្យនេះ ពេលយើងស្ដាប់អត្ថបទណែនាំឲ្យយើងត្រូវតែភ្ញាក់នៅក្នុងជីវិតរបស់យើងយ៉ាងពិសេស ធ្វើដូចម្ដេចដើម្បីមានលក្ខខណ្ឌដូចព្រះជាម្ចាស់ ធ្វើដូចម្ដេចដើម្បីទៅជាមនុស្សដ៏វិសុទ្ធដូចព្រះជាម្ចាស់ដែលជាព្រះដ៏វិសុទ្ធ។ ព្រះយេស៊ូមានព្រះបន្ទូលថា "**យើងត្រូវតែស្រឡាញ់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ព្រមទាំងទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យអស់អ្នកដែលបៀតបៀនអ្នករាល់គ្នាផង**"។ ព្រះយេស៊ូអញ្ជើញយើងឲ្យស្រឡាញ់មនុស្សទាំងឡាយដូចព្រះជាម្ចាស់មានន័យថាយើងស្រឡាញ់ទាំងមិត្តទាំងសត្រូវ។

**តើយើងត្រូវធ្វើដូចម្ដេច ដើម្បីទៅជាមនុស្សពេញលក្ខណៈដូចព្រះជាម្ចាស់?**

**តើយើងត្រូវធ្វើដូចម្ដេច ដើម្បីធ្វើជាមនុស្សដ៏វិសុទ្ធដូចព្រះជាម្ចាស់ជាព្រះដ៏វិសុទ្ធ?**

យើងមានបីចំនុចដ៏ចំខាន់បំផុត៖

ទីមួយព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណាយ៉ាងណាឲ្យយើងមានចិត្តមេត្តាករុណាយ៉ាងនោះដែរ ព្រះជាម្ចាស់លើកលែងទោសឲ្យយើង ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោស។ ពេលយើងទទួលការលើកលែងទោសពីព្រះអង្គហើយ ឲ្យយើងអនុវត្តការលើកលែងទោសដូចព្រះបិតាដែរ។

ទីពីរ ព្រះជាម្ចាស់ដែលជាព្រះដ៏វិសុទ្ធ ព្រះអង្គបានដាក់ខ្លួនយ៉ាងទាបពំផុត និងព្រះជាម្ចាស់អញ្ជើញយើងឲ្យយើងទទួលព្រះអង្គជាព្រះបិតា ពេលយើងនិយាយថាឱព្រះបិតាយើងខ្ញុំអើយ មានន័យថា យើងទទួលស្គាល់ថាយើងជាបុត្រធីតារបស់ព្រះបិតា។ ហេតុនេះហើយនៅក្នុងជីវិតរបស់យើង យើងត្រូវដាក់ខ្លួនដើម្បីទីពឹងលើព្រះជាម្ចាស់ ទន្ទឹងរងចាំសេចក្ដីស្រឡាញ់ ជីវិត កម្លាំង សេច

ក្ដីសង្ឃឹម អនាគតពីព្រះជាម្ចាស់តែម្ដង។ នៅពេលយើងទទួលស្គាល់ថា យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ យើងត្រូវការមានជីវិតដូចកូនក្មេងម្នាក់ដែលទីពឹងទាំងស្រុងទៅលើឪពុកម្ដាយ។

ទីបី សេចក្ដីស្រឡាញ់ យើងធ្វើដូចម្ដេចដើម្បីមានចិត្តស្រឡាញ់ដូចព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់។ សន្ដីតេរេសាធ្លាប់និយាយថា **"ខ្ញុំចង់ធ្វើជាមនុស្សដ៏វិសុទ្ធ នៅពេលខ្ញុំទៅស្ថានបរមសុខខ្ញុំជាមនុស្សយ៉ាងណា? ពោរពេញដោយសេចក្ដីស្រឡាញ់យ៉ាងណា?"** សន្ដីតេរេសា គាត់មើលឃើញស្ថានបរមសុខបីដូចជាចំការផ្កាមួយយ៉ាងធំ ដែលមានផ្កាគ្រប់មុខ ព្រឹកឡើងមានទឹកសន្សើមដែលអាចចូលនៅក្នុងផ្កាទៅតាមសមត្ថភាពរបស់ផ្កា ជីវិតរបស់យើងក៏ដូចគ្នានៅទីនេះមានខ្លះជាផ្កាកូលាប មានខ្លះជាផ្កាលីលី មានខ្លះជាផ្កាក្រដាស មានខ្លះជាផ្កាម៉ាលីស មានខ្លះជាផ្ការំដួល តាមសមត្ថភាពរបស់យើង យើងអាចទទួលសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដូចទឹកសន្សើម។ សំខាន់ឲ្យយើងបើកដួងចិត្តរបស់យើង ដើម្បីទទួលសេចក្ដីស្រឡាញ់របស់ព្រះអង្គតាមសមត្ថភាពរបស់យើងរៀងៗខ្លួនដែលខិតខំអស់ពីសមត្ថភាពផ្ទាល់ខ្លួន។ នេះជារបៀបដើម្បីធ្វើជាមនុស្សដ៏វិសុទ្ធមេត្តាករុណាប្រណីសន្ដោស ដាក់ខ្លួន និងស្រឡាញ់។

ថ្ងៃនេះជាថ្ងៃដែលយើងគោរព៤០០ឆ្នាំ ដែលយើងបានទទួលព្រះអំណោយទានយ៉ាងពិសេសពីសន្ដវ៉ាំងសង់ឌឺប៉ូល ដែលជាគ្រីស្ដទូតនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍និងសម្រាប់ពិភពលោកទាំងមូល។ ដោយសារសន្ដវ៉ាំងសង់ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ បានទៅគ្រប់ទីកន្លែង ក្នុងជីវិតរបស់សន្ដវ៉ាំងសង់គាត់បានទទួលការត្រាស់ហៅមួយយ៉ាងពិសេសធ្វើដូចម្ដេចដើម្បីឲ្យសេចក្ដីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ ចូលជាមួយសេចក្ដីស្រឡាញ់ដែលយើងត្រូវតែមានសម្រាប់បងប្អូនឯទៀតៗ។ យើងពូកែគិតនិងមានគំនិតអស្ចារ្យពីសេចក្ដីស្រឡាញ់ ប៉ុន្តែអ្វីដែលសំខាន់បំផុតគឺធ្វើដូចម្ដេច ដើម្បីអនុវត្តសេចក្ដីស្រឡាញ់នោះចំពោះបងប្អូនទាំងឡាយ។ មានន័យថាឲ្យសេចក្ដីស្រឡាញ់ដែលយើងមាននៅក្នុងចិត្ត យើងចែកទៅដល់បងប្អូនឯទៀតៗ។

នៅឆ្នាំ១៦១៧សន្ដវ៉ាំងសង់ឌឺប៉ូលបានទទួលបទពិសោធន៍ពីរដ៏សំខាន់៖

ទីមួយ គាត់រស់នៅប្រទេសបារាំង ដែលសម័យនោះគ្មានការអភិវឌ្ឍទេ គេបានហៅគាត់ដើម្បីជួបជាមួយកសិករម្នាក់ដែលក្រនិងជិតស្លាប់។ កសិករម្នាក់នោះបានសុំទទួលអគ្គសញ្ញាលើកលែងទោសចុងក្រោយរបស់គាត់ ដោយគាត់បាននិយាយអំពីជីវិត អំពីអំពើបាបដែលជាលើកទីមួយគាត់អាចនិយាយបានទាំងអស់ ធ្វើឲ្យសន្ដវ៉ាំងសង់ភ្ញាក់ពេលស្ដាប់ភាពក្រីក្រតាមផ្លូវវិញ្ញាណ ពេលស្ដាប់អំពើបាបនិងទុក្ខលំបាករបស់កសិករនេះ ធ្វើឲ្យគាត់យល់ថាខ្ញុំមានតួនាទីមួយយ៉ាងពិសេស ធ្វើដូចម្ដេចដើម្បីសង្គ្រោះចិត្តគំនិតរបស់មនុស្ស ដែលកំពុងមានទុក្ខលំបាក ដែលកំពុងជាប់ជាមួយអំពើបាប ដើម្បីរកឃើញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់និងដើម្បីទទួលជីវិតថ្មី។ នេះជាបទពិសោធទី

មួយរបស់គាត់ គឺបទពិសោធខាងផ្លូវវិញ្ញាណ ភាពក្រីក្រខាងផ្លូវវិញ្ញាណ ធ្វើដូចម្ដេចដើម្បីជួយប្រជាជនយ៉ាងច្រើន ឲ្យគេរកឃើញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់នឹងទទួលជីវិតថ្មីនៅក្នុងព្រះជាម្ចាស់តែម្ដង។

ទីពីរក្នុងឆ្នាំដដែល គេហៅគាត់ទៅជួបអ្នកជំងឺម្នាក់ដែលកំពុងរងទុក្ខលំបាកខ្លាំង សន្តវ៉ាំងសង់បានខិតខំប្រកាសដើម្បីប្រមូលលុយជួយអ្នកជំងឺម្នាក់នោះ ពេលនោះធ្វើឲ្យគាត់សប្បាយចិត្តដោយសារមានបងប្អូនជួយច្រើន ដែលយើងអាចសង្គ្រោះនិងជួយគ្នាទៅវិញទៅមកបាន។ មានអ្នកជំងឺ ក្មេងកំព្រា ស្ត្រីមេម៉ាយ ជនអនាថាច្រើនណាស់ ធ្វើឲ្យគាត់បង្កើតសមាគមនៃធម៌មេត្តាករុណាជាមួយស្ត្រីទាំងអ្នកមានទាំងអ្នកក្រីក្រ គាត់បានប្រមូលគេនិងប្រគល់តួនាទីឲ្យគេជួយអ្នកក្រីក្រតៗគ្នា។ គាត់បានបង្កើតគណកម្មការមួយយ៉ាងពិសេស ដើម្បីយកចិត្តទុកដាក់ជួយអ្នកក្រីក្រ ពីពេលនោះមកគាត់បានបន្តទៅប្រកាសដំណឹងល្អដោយមានគំនិតពីរ គឺទីមួយធ្វើដូចម្ដេចឲ្យបូជាចារ្យភ្ញាក់ស្មារតីដើម្បីណែនាំឲ្យបងប្អូនដែលក្រីក្រខាងផ្លូវវិញ្ញាណទទួលជីវិតថ្មី នៅក្នុងអគ្គសញ្ញានានា នៅក្នុងអភិបូជា នៅក្នុងជីវិតខាងផ្លូវវិញ្ញាណ។ ទីពីរ ធ្វើដូចម្ដេចដើម្បីឲ្យធម៌មេត្តាករុណាទៅដល់គ្រប់ទីកន្លែងដើម្បីឲ្យអ្នកក្រីក្រអាចមានសេចក្ដីសង្ឃឹមសារជាថ្មី។ នៅឆ្នាំ១៦២៥ គាត់បានបង្កើតសមាគមបូជាចារ្យមួយដែលមានគំនិតតែមួយ គឺដើរតាមព្រះយេស៊ូគ្រីស្តដោយប្រកាសដំណឹងល្អដល់ជនក្រីក្រ។ នៅឆ្នាំ១៦៣៣ សន្តវ៉ាំងសង់ឌីប៉ូលបានបង្កើតក្រុមបុត្រីនៃមេត្តាករុណា នៅពេលនោះគាត់បានជួយសរសេរប្រាំះ

ទីមួយ ឲ្យយើងមានភាពសមញ្ញបំផុតនៅក្នុងជីវិតរបស់យើង ដើម្បីបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតយ៉ាងស្រួល កុំឲ្យយើងគិតអំពីឋានៈ កុំឲ្យយើងគិតអំពីអ្វីៗទាំងអស់។ សន្តវ៉ាំងសង់ឌីប៉ូលជាមនុស្សពិសេស គាត់ជាអ្នកទទួលខុសត្រូវអប់រំកូនក្មេងអ្នកមានបំផុតខាងទាហាននៅប្រទេសបារាំង គាត់បានស្គាល់ម្ចាស់ស្ត្រីយ៉ាងច្រើន ប៉ុន្តែជីវិតរបស់គាត់ធម្មតាគាត់មិនដែលធ្វើអ្វីពិសេស ប៉ុន្តែគាត់ចេះបង្កើតទំនាក់ទំនងដើម្បីណែនាំគេឲ្យចេះមើលអ្នកក្រីក្រនៅក្នុងជីវិតសមញ្ញរបស់គាត់។

ទីពីរ គាត់អញ្ជើញយើងឲ្យយើងចេះដាក់ខ្លួនជានិច្ចដោយមើលឃើញព្រះជាម្ចាស់ ពេលយើងនិយាយថាដាក់ខ្លួនជូនកាលយើងពិបាកទទួលនៅក្នុងជីវិតយើង តែឲ្យយើងមើលព្រះជាម្ចាស់ទៅ ព្រះជាម្ចាស់បានចាប់កំណើតជាមនុស្សនៅក្នុងភូមិបេថ្លេហិម ក្នុងគ្រោលសត្វនេះជាការដាក់ខ្លួនបំផុតរបស់ព្រះជាម្ចាស់។ ម្យ៉ាងទៀតព្រះជាម្ចាស់ បានសោយទិវង្គត់លើឈើឆ្កាងដែលជារបៀបដាក់ខ្លួនដល់កំពូល។ មុនសោយទិវង្គត់លើឈើឆ្កាង ព្រះអង្គបានលាងជើងឲ្យក្រុមសាវ័ក ដូច្នេះជីវិតរបស់ព្រះយេស៊ូតាំងពីចាប់កំណើតជាមនុស្ស លាងជើង និងសោយទិវង្គត់ ជាជីវិតដាក់ខ្លួនដល់កំពូល នេះជាអ្វីដែលព្រះជាម្ចាស់សំណូមពរយើងតាមរយៈសន្តវ៉ាំងសង់ឌីប៉ូល។

ទីបី សូមឲ្យមានចិត្តស្លូតបូតដើម្បីបង្កើតទំនាក់ទំនងជាមួយអ្នកតូចតាច ដែលកំពុងមានទុក្ខលំបាក។ នៅឆ្នាំ១៦៣៩ សន្តវ៉ាំងសង់ឌឺប៉ូល គាត់បានទទួលកុមារកំព្រាម្នាក់រាល់ថ្ងៃ ក្រោយមកទទួលចាស់ជរានិងអ្នកជំងឺ។ អ្វីដែលគាត់ធ្វើគឺគ្មានគម្រោងការណ៍ច្បាស់លាស់ គ្មានអង្គការ គឺគាត់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដោយជិតស្និតជាមួយព្រះសហគមន៍។ គាត់បានរស់នៅជាមួយលោកអភិបាល ជាមួយបូជាចារ្យ ដោយបានណែនាំឲ្យព្រះសហគមន៍ភ្ញាក់ស្មារតីដើម្បីទៅជាព្រះសហគមន៍របស់ព្រះគ្រីស្ត ដោយចេះបម្រើ ដោយចេះស្រឡាញ់ ដោយចេះលើកលែងទោស ដោយចេះយកចិត្តទុកដាក់ជាពិសេសជាមួយអ្នកតូចតាច។

ទីបួន យកចិត្តទុកដាក់លះបង់ចោលផលប្រយោជន៍ លីឈើឆ្កាង សុខចិត្តបូជាខ្លះៗ។ បើបងប្អូនសុខចិត្តអនុវត្តអ្វីដែលយើងមានក្នុងភាគភ្នំពេញ អាទិត្យទីមួយយើងអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ អាទិត្យទីពីរយើងសូត្រផ្គាំសម្រាប់ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ អាទិត្យទីបីយើងតមអាហារ អាទិត្យទីបួនយើងទៅអធិដ្ឋាននៅអរិយក្សត្រ។ ដែលទាំងអស់នេះជារបៀបដែលយើងលះបង់ចោលខ្លះៗ ដើម្បីតស៊ូនៅក្នុងជីវិតរបស់យើង ដើម្បីយកចិត្តទុកដាក់អធិដ្ឋាន និងដើម្បីមានផ្លែច្រើនសម្រាប់បងប្អូនឯទៀតៗ។

ទីប្រាំ យកចិត្តទុកដាក់ដោយសេចក្តីស្រឡាញ់យ៉ាងខ្លាំង យកចិត្តទុកដាក់ដល់កំពូលដោយបង្ហាញសេចក្តីស្រឡាញ់គ្រប់ពេលវេលា។ ពេលចុងក្រោយរបស់គាត់ មានគេសួរគាត់ថា តើអស់មួយជីវិតរបស់លោក មានអ្វីខ្លះៗដែលលោកគិតថាមិនទាន់បានធ្វើគ្រប់គ្រាន់? គាត់បានឆ្លើយតបនឹងគេវិញថា គឺខ្ញុំមិនបានស្រឡាញ់គេល្មមទេ។ ពេលគាត់និយាយដូចនេះ ណែនាំឲ្យយ៉ងភ្ញាក់ដោយសារជីវិតរបស់គាត់ជាជីវិតដែលពោរពេញដោយសេចក្តីស្រឡាញ់ ជាជីវិតដែលចែករំលែកសេចក្តីស្រឡាញ់ដើម្បីធ្វើជាអ្នកដ៏វិសុទ្ធ ដូចព្រះបិតាជាព្រះដ៏វិសុទ្ធ។ នេះជាកម្លាំងមួយសម្រាប់យើង ដោយដឹងថាពេលយើងបានសាងសង់ផ្ទះមួយឲ្យគេ យើងបានជូនម្ហូបអាហារឲ្យគេ បានជួយគេ កុំឲ្យយើងគិតថាល្មមហើយ។ អស់មួយជីវិតរបស់យើងដែលជាសមាជិកក្រុមសន្តវ៉ាំងសង់ឌឺប៉ូលជាគ្រីស្តបរិស័យក៏ដោយ យើងត្រូវធ្វើដូចម្តេចដើម្បីណែនាំឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គយាងចូលនៅក្នុងជីវិតរបស់យើងផ្ទាល់ ដូចទឹកសន្សើមនៅលើផ្កាពេលព្រឹក ធ្វើដូចម្តេចដើម្បីឲ្យសេចក្តីស្រឡាញ់ហៀរចេញពីដួងចិត្តរបស់យើង ដើម្បីណែនាំឲ្យសង្គមរបស់យើងទៅជាសង្គមថ្មី។

សន្តវ៉ាំងសង់ឌឺប៉ូលធ្លាប់និយាយថា **"សេចក្តីស្រឡាញ់អត់មានព្រំដែនសោះ"** យើងអាចមានគំនិតថ្មីៗ ដើម្បីបង្កើតសកម្មភាពធម៌មេត្តាករុណា។ សេចក្តីស្រឡាញ់ចេញពីដួងចិត្តរបស់យើង នឹងណែនាំឲ្យយើងអាចមានសកម្មភាព និងស្នារដៃច្រើន ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅគ្រប់ទីកន្លែង។ យើងមានអំណរសប្បាយ សូមព្រះជាម្ចាស់ប្រទានពរតាមរយៈសន្តវ៉ាំងសង់ឌឺប៉ូល យើងទៅជាអ្នកដ៏វិសុទ្ធដូចព្រះបិតាជាព្រះដ៏វិសុទ្ធ។ អាម៉ែន។